ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

ណុំរឿងក្តីរដ្ឋប្បវេណីលេខ ២៣៥

ប.អ.ស/២៥-០៥-២០២៣។

សាលក្រមលេខ៤៣ ( ដ )/២៨៨

ុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការលេខ០១ ( ខ ) អគារ( ខ ) ។

កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០១ខែកញ្ញា ឆ្នាំ២០២៣ វេលាព្រឹក ។

កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃសុក០១រោចខែស្រាពណ៍ឆ្នាំថោះ បញ្ចស័កព.ស២៥៦៧ ត្រូវនិងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ វេលាព្រឹក ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប ។

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប ។

### ដើមចោទ

-ឈ្មោះ [redacted] ផុក ភេទស្រីកើតនៅឆ្នាំ១៩៩៣ សញ្ជាតិខ្មែរមានទីលំនៅបច្ចុប្បន្ន [redacted] ដោយមានលោកស្រី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

### ចុងចម្លើយ

-ឈ្មោះ [redacted] សំ ភេទប្រុសកើតនៅឆ្នាំ១៩៩២ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។

កម្មវត្ថុ : ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម:

១-ឱ្យដើមចោទឈ្មោះ [redacted] ផុក លែងលះពីចុងចម្លើយឈ្មោះ [redacted] សំ ។

២-ឱ្យដើមចោទឈ្មោះ [redacted] ផុក មានសិទ្ធិអំណាចមេបាគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាលើកូនប្រុសស្រីចំនួន០២នាក់ ដែលមានឈ្មោះ [redacted] សុទ្ធាវិទ្ធី ភេទប្រុស កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤ និងឈ្មោះ [redacted] រដ្ឋា ភេទស្រី កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ ។

៣-ឱ្យចុងចម្លើយឈ្មោះ [redacted] សំ បង់សោហ៊ុយសម្រាប់ចិញ្ចឹមកូនចំនួន០២នាក់ តាមលទ្ធភាព ។

៤-ចំពោះប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

អង្គហេតុជាមូលហេតុនៃការទាមទារ :

Scanned with CamScanner

នៅក្នុងអំឡុងឆ្នាំ២០១២ ដើមចោទឈ្មោះ[redacted]ផុក ភេទស្រីនិងចុងចម្លើយឈ្មោះ[redacted]សំ បានរៀការជាមួយគ្នាតាមច្បាប់ ហើយបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នានៅសាលាឃុំឫស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប លេខ១២ ចុះថ្ងៃទី០៦ ខែមេសាឆ្នាំ២០១២ ។ ក្រោយរៀមការរួច ភាគីទាំងពីរបានរស់នៅជាមួយគ្នាបង្កើតបានកូនប្រុសស្រីចំនួន០២នាក់មានឈ្មោះសំ សុទ្ធ រិទ្ធី ភេទប្រុសកើតនៅឆ្នាំ២០១៤និងកូនស្រីឈ្មោះ[redacted]រដ្ឋា កើតនៅឆ្នាំ២០១២ ។ក្នុងការរស់ជាមួយគ្នាកន្លងមកគូភាគីតែងតែ មានគំនិតខ្វែងគ្នាមិនចុះសម្រុងនិងគ្នារហូត ចុងចម្លើយមិនបានរកលុយជួយផ្គត់ផ្គង់គ្រួសារនិងចិញ្ចឹមកូនទេដើរលេងច្រើន.ចូលក្លឹប កំសាន្តជារាងរាល់សប្តាហ៍និងប្រើប្រាស់នូវសារធាតុញៀនជាញឹកញាប់ ទោះបីដើមចោទជាប្រពន្ធហាមឃាត់យ៉ាងណាតែចុងចម្លើយជាប្តីនៅតែប្រព្រឹត្តដដែលជារាងរហូតទ្រព្យសម្បត្តិរួមក៏គ្មានដែរ ។ ហេតុផលទាំងនេះហើយដែលធ្វើដើមចោទជាប្រពន្ធស៊ូទ្រាំរស់នៅជាមួយចុងចម្លើយតទៅទៀតមិនបានទើបនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ដើមចោទជាប្រពន្ធសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយជាប្តីតែម្តង ។

**នាពេលទាញហេតុផលផ្ទាល់មាត់**

**-ដើមចោទឈ្មោះ[redacted] ផុក ដែលមានមេធាវីឈ្មោះ[redacted] សុធារី** ជាអ្នកតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា នៅពេលនេះខ្លួននៅតែប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះពើយ [redacted] ដដែល ដោយសំអាងថា នៅក្នុងអំឡុងឆ្នាំ២០១២ ខ្លួននិងចុងចម្លើយឈ្មោះ[redacted]សំ បានរៀការជាមួយគ្នាតាមច្បាប់ ហើយបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជា មួយគ្នានៅសាលាឃុំឫស្សីលក ស្រុកជីក្រែង ខេត្តសៀមរាបលេខ១២ ចុះថ្ងៃទី០៦ ខែមេសាឆ្នាំ២០១២ ។ ក្រោយរៀមការរួច ខ្លួនទាំងពីរបានរស់នៅជាមួយគ្នាបង្កើតបានកូនប្រុសស្រីចំនួន០២នាក់មានឈ្មោះ[redacted]សុទ្ធ រិទ្ធី ភេទប្រុសកើតនៅឆ្នាំ២០១៤ និងកូនស្រីឈ្មោះ[redacted] រដ្ឋា កើតនៅឆ្នាំ២០១២ ។ក្នុងការរស់ជាមួយគ្នាកន្លងមកខ្លួនជាមួយចុងចម្លើយតែងតែមានគំនិតខ្វែងគ្នាមិនចុះសម្រុងនិងគ្នារហូតចុងចម្លើយមិនបានរកលុយជួយផ្គត់ផ្គង់គ្រួសារនិងចិញ្ចឹមកូនទេដើរលេងច្រើន.ចូលក្លឹបកំសាន្តជារាងរាល់សប្តាហ៍ និងប្រើប្រាស់នូវសារធាតុញៀនជាញឹកញាប់ ទោះបីខ្លួនបានហាមឃាត់យ៉ាងណាចុងចម្លើយនៅតែប្រព្រឹត្តដដែលជារាងរហូតមកទ្រព្យសម្បត្តិរួមក៏គ្មានដែរ ។ហេតុផលទាំងនេះហើយដែលធ្វើឱ្យខ្លួនជាប្រពន្ធស៊ូទ្រាំរស់នៅជាមួយចុងចម្លើយតទៅទៀតមិនបាន ម្យ៉ាងទៀតខ្លួនអស់មនោសញ្ចេតនាជាប្តី ប្រពន្ធជាមួយចុងចម្លើយតទៅទើបនៅថ្ងៃទី២៩ខែឧសភាឆ្នាំ២០២៣ខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយតែម្តង ។នៅក្នុងរឿងនេះខ្លួនសុំសិទ្ធគ្រប់គ្រងនិងចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ចំពោះសោហ៊ុយសម្រាប់ចិញ្ចឹមកូនទាំងពីនាក់ខ្លួនមិនទាមទារឱ្យចុងចម្លើយចិញ្ចឹមទេតាមលទ្ធភាពរបស់ចុងចម្លើយក្នុងការផ្តល់សោហ៊ុយសម្រាប់ចិញ្ចឹមកូនទាំងពីរនាក់ ហើយនៅពេលនេះដែរខ្លួនសុំលះបង់នូវការទាមទារសំណងជម្ងឺផ្សេងទៀតទាំងអស់ ពីចុងចម្លើយ ។

-ចុងចម្លើយឈ្មោះ[redacted] សំ មិនបានធ្វើសេចក្តីថ្លែងការណ៍តបទៅដើមចោទវិញទេព្រោះចុងចម្លើយអវត្តមានតាំងពីនៅនីតិវិធីដំណាក់កាលត្រៀមរហូតដល់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយចុងចម្លើយមិននៅលំនៅដ្ឋានទេចុងចម្លើយបានចាកចេញពីផ្ទះទៅរស់នៅខេត្តផ្សេង ។

**-ចំណុចវិវាទនិងចំណុចគ្មានវិវាទ :**

-ចំណុចមានវិវាទ :គ្មាន ។

-ចំណុចគ្មានវិវាទ:គ្មាន ។

Scanned with CamScanner

៣-ការពិនិត្យភស្តុតាង

-ភស្តុតាងមាន :

-សំបុត្រអាពាហ៍ពិពាហ៍លេខលេខ១២/២០១២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២( ថតចម្លង០១ច្បាប់ ) ។

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ[redacted]ថុក លេខ៤០៣៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥( ថតចម្លងចំនួន០១ច្បាប់ ) ។

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ[redacted]ដ្ឋា លេខ៧៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣ ( ថតចម្លងចំនួន០១ច្បាប់ ) ។

-សំបុត្របញ្ជាក់កំណើតរបស់ឈ្មោះ[redacted]សុទ្ធារិទ្ធ លេខ៧៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៤ ( ថតចម្លងចំនួន០១ច្បាប់ ) ។

-សំអាងហេតុ :

ការប្ដឹងសុំលែងលះ

-សេចក្ដីថ្លែងការណ៍និងការអះអាងដំបូងរបស់ភាគីដើមចោទបញ្ជាក់ថាខ្លួនអស់មនោសញ្ចេតនានិងរួមរស់នៅជាមួយគ្នា តទៅទៀត ហើយ ការថ្លែងរបស់ភាគីដើមចោទត្រូវបានភាគីចុងចម្លើយបដិសេធ( ព្រោះអវត្តមានរបស់ភាគីចុងចម្លើយ ) ។

១-ចំពោះចំណុចទី១នៃពាក្យបណ្ដឹង ដើមចោទឈ្មោះ[redacted] ថុក បានប្ដឹងទាមទារលែងលះពីចុងចម្លើយឈ្មោះ[redacted] សំ ដោយសំអាងហេតុថាខ្លួនបានរៀបការត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ២០១២ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ហើយដើមចោទបានលើកឡើងថាខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយ ហើយចុងចម្លើយមិនបានបដិសេធទេ។

២-ចំពោះចំណុចទី២ នៃពាក្យបណ្ដឹង ដើមចោទបានទាមទារគ្រប់គ្រងកូនប្រុសស្រីទាំង០២នាក់មាន**ឈ្មោះ**[redacted]វដ្ដា ភេទស្រី កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ និងឈ្មោះ[redacted]សុទ្ធារិទ្ធ ភេទប្រុសកើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤ចិញ្ចឹមបីបាច់ថែរក្សានិងបានលះបង់នូវសោហ៊ុយទុកសម្រាប់ចិញ្ចឹមកូនរបស់ខ្លួន ។ ហេតុដូច្នេះតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ ។ តែឱ្យភាគីចុងចម្លើយមានសិទ្ធិសួរសុខទុក្ខដល់កូនបានហើយភាគីដើមចោទត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីចុងចម្លើយ ក្នុងការជួបកូនប៉ុន្តែភាគីចុងចម្លើយត្រូវមកសួរសុខទុក្ខកូនបានរាល់ចុងសប្ដាហ៍ ដូចជាថ្ងៃសៅរ៍ និងថ្ងៃអាទិត្យដើម្បីងាយស្រួលដល់ការសិក្សាកូន ។ ដូច្នេះភាគីចុងចម្លើយត្រូវមកសួរសុខទុក្ខកូននៅចន្លោះពីម៉ោង១១ព្រឹករហូតដល់ ម៉ោង៥ល្ងាច ។

**៣-ចំពោះចំណុច៣** នៃពាក្យបណ្ដឹងខាងលើ នៅពេលដំណាក់កាលនីតិវិធីត្រៀមនិងនៅដំកាលទាញហេតុផ្ទាល់មាត់តាម ការអះអាងរបស់ភាគីដើមចោទឈ្មោះ [redacted] ថុក បានបញ្ជាក់ចំពោះសោហ៊ុយសម្រាប់ចិញ្ចឹមកូនទាំងពីរនាក់ខ្លួនសុំលះ បង់ចោលមិនទាមទារពីចុងចម្លើយទេទុកឱ្យចុងចម្លើយជួយចិញ្ចឹមតាមលទ្ធភាពចុះការអះអាងរបស់ភាគីដើមចោទត្រូវបានតុលាការជឿជាក់និងលើក យកមកពិចារណា។ ដូច្នេះតុលាការគប្បីសម្រេចតាមការទាមទាររបស់ភាគីដើមចោទ។

**៤-ចំពោះចំណុច៤** នៃពាក្យបណ្ដឹងខាងលើ នៅពេលដំណាក់កាលនីតិវិធីត្រៀមនិងនៅដំកាលទាញហេតុផ្ទាល់មាត់តាម ការអះអាងរបស់ភាគីដើមចោទឈ្មោះ[redacted]ថុក បានបញ្ជាក់ខ្លួនសុំលះបង់ចោលមិនទាមទារឱ្យភាគីបង់សំណងការខូចខាតនិងជំងឺចិត្ត ចំនួន២លានរៀលមកឱ្យខ្លួនជាដើមចោទទេការអះអាងរបស់ភាគីដើមចោទនៅពេលនេះតុលាការមិនលើកយកមកពិចារណាទេ។ ដូច្នេះតុលាការគប្បីសម្រេចធ្វើការច្រានចោលការតាមការទាមទារនិងការអះអាងរបស់ភាគីដើមចោទ ព្រោះច្បាប់មិនបានចែង។

Scanned with CamScanner

៦-តុលាការបានបញ្ជូនដីកាកោះឱ្យចូលរួមក្នុងនីតិវិធី តែចុងចម្លើយមិនបានចូលរួមនីតិវិធីរបស់តុលាការ ដោយមិនមានមូលហេតុ។

៦-ចំពោះចំណុច៦ នៃពាក្យបណ្តឹងខាងលើ នៅពេលទាមញហេតុផ្ទាល់មាត់តាមការអះអាងរបស់ភាគីដើមចោទ ឈ្មោះ [redacted] ថ៊ុក ថាប្រាក់ប្រដាប់ក្តីនិងប្រាក់ពន្ធផ្សេងៗទៀតជាបន្ទុករបស់ខ្លួនដោយហេតុថាជាកំហុសរបស់ខ្លួនជាអ្នកដាក់ពាក្យបណ្តឹង ការលើកឡើងបែបនេះត្រូវបានភាគីចុងចម្លើយយល់ព្រមនិងឯកភាព ។ ហេតុដូច្នេះតុលាការសម្រេចទៅតាមការទាមទាររបស់ភាគី ដើមចោទ ។

**ហេតុដូច្នេះសម្រេចបញ្ចប់**

**១-ទទួលពាក្យបណ្តឹងលេខ ២៣៥ ចុះថ្ងៃទី២៩ ខែឧសភាឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ[redacted] ថ៊ុក ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។**

២-ឱ្យដើមចោទឈ្មោះ [redacted]**ថ៊ុក** និងចុងចម្លើយឈ្មោះ [redacted] **សំ លែងលះពីគ្នា** ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១២/២០១២ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ ។

៣-ប្រគល់សិទ្ធិគ្រប់គ្រងនិងមានអំណាចមេបាលើកូនប្រុសស្រីចំនួន០២នាក់មាន **ឈ្មោះ**[redacted]វដ្តា ភេទស្រី កើតនៅ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២ និងឈ្មោះ[redacted]សុទ្ធារិទ្ធ ភេទប្រុសកើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤ ឱ្យទៅដើមចោទគ្រប់គ្រងថែរក្សា និងឱ្យចុងចម្លើយឈ្មោះ[redacted] សំ ផ្តល់សោហ៊ុយតាមលទ្ធភាពដល់ដើមចោទឈ្មោះ[redacted] ថ៊ុក ទុកសម្រាប់ចិញ្ចឹមកូនទាំង០២នាក់រហូតដល់កូនទាំង០២នាក់ធំពេញវ័យ ។ រីឯភាគីដើមចោទត្រូវផ្តល់ពេលវេលាឱ្យចុងចម្លើយចូលទៅសួរសុខទុក្ខដល់កូនបាន នៅចន្លោះពេលពីម៉ោង១១ព្រឹករហូតដល់ម៉ោង ៥ល្ងាចជារាងរាល់ចុងសប្តាហ៍។

៤- ឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ វេលាព្រឹក នៅចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និងបានប្រកាសសាលក្រមនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ វេលាព្រឹកនៅចំពោះមុខភាគីដើម ចោទ កំបាំងមុខចុងចម្លើយ ។

ថ្ងៃសុក្រ០១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣។

**ចៅក្រម**

**ហត្ថលេខានិងត្រា** [redacted]

---

**បានឃើញ**

**សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣**

**ចៅក្រម**

[redacted]

**បានវាយចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។**

ថ្ងៃសុក្រ០១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

**សៀមរាប ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ ។**

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner